CITY OF LONG BEACH

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ
411 West Ocean Boulevard, Lobby
Long Beach, CA 90802
(562) 570-7600

# ពាក្យសុំបង់ប្រាក់តាមដំណាក់កាល

ពាក្យសុំនេះគឺជាសំណើមួយ ដើម្បីសុំបង់ប្រាក់តាមដំណាក់កាល ពាក់ព័ន្ធនឹងប្រាក់ថ្លៃអាជ្ញាប័ណ្ណអាជីវកម្ម ថ្លៃសុខភាព និងវិក្កយបត្រឯទៀតរបស់សាលាក្រុង (រួមទាំងថ្លៃពិន័យចំពោះការចតយានយន្ត និងថ្លៃទឹកភ្លើង) ដែលស្ថិតក្រោមកម្មវិធីបង់ប្រាក់តាមដំណាក់កាលដែលមានភាពបត់បែន។ សូមបំពេញព័ត៌មានខាងក្រោមនេះ កុំឲ្យមានខ្វះចន្លោះ។

បើអ្នកមានចម្ងល់អំពីកម្មវិធីនេះ ឬសុំពឹងឲ្យជួយបំពេញពាក្យសុំនេះ សុំទាក់ទងយើងខ្ញុំតាមអ៊ីម៉េលនេះ៖ FM-CityCollections@longbeach.gov ឬទូរស័ព្ទទៅលេខនេះ៖ (562) 570-7600។

| | |
|---|---|
| **ឈ្មោះពេញ៖** | |
| **ឈ្មោះអាជីវកម្ម៖** | |
| **អាសយដ្ឋានទាំងស្រុង៖** *(រួមទាំងទីក្រុង រដ្ឋ និង zip code)* | |
| **លេខទូរស័ព្ទ៖** *(រួមទាំងលេខកូដតំបន់ផង)* | |
| **អាសយដ្ឋានអ៊ីម៉េល៖** | |
| **ប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណលេខ៖** | |
| **គណនីលេខ៖** *(មាននៅលើវិក្កយបត្ររបស់អ្នក/សេចក្តីជូនដំណឹង)* | |

## លក្ខខណ្ឌ

- ពុំមានបង់ថ្លៃសម្រាប់ពាក្យសុំនេះ ឬថ្លៃសម្រាប់ការសុំបង់តាមដំណាក់កាលនេះនោះឡើយ។
- ការបង់ប្រាក់តាមដំណាក់កាលនេះ គឺតម្រូវឲ្យអ្នកបង់នូវទឹកប្រាក់កំណត់ទាបបំផុតណាមួយជាប្រចាំខែ ដោយផ្អែកលើចំនួនសរុប ដែលមាននៅក្នុងគម្រោងបង់ប្រាក់តាមដំណាក់កាលនោះ ដែលអាចមានរយៈពេលរហូតដល់ ១៨ខែ។
- ការចុះឈ្មោះដើម្បីសុំបង់ប្រាក់តាមដំណាក់កាលនេះ គឺពុំគិតថ្លៃទូទាត់ប្រាក់យឺត និងថ្លៃពិន័យនោះឡើយ ប៉ុន្តែទាល់តែអ្នកបំពេញតាមលក្ខខណ្ឌរបស់កម្មវិធីនេះ។
- ពុំមានការពិន័យនោះទេ បើអ្នកបង់ផ្តាច់នៅមុនថ្ងៃផុតកំណត់នៃរយៈពេលបង់តាមដំណាក់កាលនោះ។
- កម្មវិធីនេះមានផ្តល់ការពន្យាររយៈពេល ៤៥ថ្ងៃ បានម្តងសម្រាប់ការបង់ប្រាក់យឺត។
- អ្នកនឹងត្រូវបង់ថ្លៃលុបចោលគម្រោងនេះ ហើយថ្លៃពិន័យផ្សេងៗនឹងកើតមានឡើងវិញ បើក្រោយពីការពន្យាររយៈពេល ៤៥ថ្ងៃនោះបានផុតទៅ អ្នកនៅតែពុំបានទូទាត់ប្រាក់ឲ្យបានទៀងទាត់ ឬអ្នកមិនបានបង់ប្រាក់ឲ្យបានគ្រប់ចំនួន នៅត្រឹមថ្ងៃផុតកំណត់នៃរយៈពេលបង់តាមប្រាក់ដំណាក់កាលនោះ។
- ការទូទាត់ប្រាក់ដែលពុំមានសាច់ប្រាក់ទូទាត់ នឹងឈានទៅដល់ការលុបគម្រោងបង់ប្រាក់តាមដំណាក់កាលនេះ។

- គម្រោងបង់ប្រាក់តាមដំណាក់កាលនេះ កាលណាលុបចោលហើយ គឺមិនអាចបង្កើតឡើងវិញបានសម្រាប់វិក្កយបត្រ/ការបង់ថ្លៃដដែលនោះឡើយ។ មិនតែប៉ុណ្ណោះ គម្រោងបង់ប្រាក់តាមដំណាក់កាលដែលកំពុងជំពាក់នោះ ក៏លែងមានការពន្យានិងពិនិត្យឡើងវិញនោះដែរ។

ខ្ញុំសូមធានាបញ្ជាក់ចំពោះមុខច្បាប់ ថារាល់ពាក្យពេចន៍ និងព័ត៌មានទាំងអស់នេះ គឺពិតនិងត្រឹមត្រូវ។ បើព័ត៌មានណាមួយមិនពិត ឬមិនពេញលេញ នោះគម្រោងសុំបង់ប្រាក់តាមដំណាក់កាលនេះ នឹងត្រូវលុបចោល។ ខ្ញុំសូមធានាបញ្ជាក់បន្ថែមទៀតថា ការណ៍ដែលខ្ញុំបានបំពេញ និងដាក់ពាក្យសុំតាមប្រព័ន្ធអេឡិចត្រូនិកនេះ គឺខ្ញុំកំពុងប្រកាសប្រាប់ថាខ្ញុំមានបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ។

ហត្ថលេខា៖ ______________________________ កាលបរិច្ឆេទ៖ ______________

**សូមផ្ញើពាក្យសុំនេះទៅ៖**

សាលាក្រុងឡុងប៊ិច ផ្នែកសេវាពាណិជ្ជកម្មសម្រាប់ប្រមូលប្រាក់ជំពាក់

តាមប្រអប់សំបុត្រ P.O. Box 630, Long Beach, CA 90842

អ៊ីម៉េល៖ FM-CityCollections@longbeach.gov